# ព្រះរាជក្រម

នស/រកម/១១១១/០១៤

យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សម្មាទិដ្ឋិធម្មិកជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

រដ្ឋសភា
ទទួល លេខ... ថ្ងៃទី... ឆ្នាំ២០១១ ម៉ោង...
បញ្ជូនទៅ...

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឲ្យប្រើ

ច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុនខេមបូឌា អ៊ិនធើរណេស្យូណាល អ៊ិនវេស្តមែន ឌីវើឡុបមែន គ្រុប ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី២ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ ៖



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល
## នៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុន ខេមបូឌា
## អ៊ិនធើរណេស្យូណាល អ៊ិនវេស្តមែន
## ឌីវើឡុបមែន គ្រុប

**មាត្រា ១.-**

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចំពោះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអគ្គិសនីកម្ពុជា ឲ្យក្រុមហ៊ុនខេមបូឌា អ៊ិនធើរណេស្យូណាល អ៊ិនវេស្តមែន ឌីវើឡុបមែន គ្រុប ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគម្រោង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនខេមបូឌា អ៊ិនធើរណេស្យូណាល អ៊ិនវេស្តមែន ឌីវើឡុបមែន គ្រុប និងកិច្ចព្រមព្រៀងទិញថាមពលអគ្គិសនី រវាងអគ្គិសនីកម្ពុជា និងក្រុមហ៊ុនខេមបូឌា អ៊ិនធើរណេស្យូណាល អ៊ិនវេស្តមែន ឌីវើឡុបមែន គ្រុប ដែលបានចុះហត្ថលេខា នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១១ ។ ការធានាទូទាត់នេះ មានអត្ថបទទាំងស្រុង ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១១ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃរាជរដ្ឋាភិបាលកម្ពុជាភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តលិខិតជានាទូទាត់នេះ ។

**មាត្រា ៣ .-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១១

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

**បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ**

**សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ**

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**គាត ឈន់**

លេខៈ ១០១៣ ប.ល

**ដើម្បីចម្លងចែក**

**រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១១**

**អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល**

**សយ សុខា**

3/3

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ៦៥ . ស/ប្រក**

## សិទ្ធិប្រទាន

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
-បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៧ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសម្បទាន
-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១០/០១៧ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១
-បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាព ជូនឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងអនុវត្តគម្រោង (Implementation Agreement) និងលើលិខិតធានាទូទាត់ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា (Governmental Guarantee of Payment) ដោយអគ្គិសនីកម្ពុជា ឬក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ទៅឱ្យក្រុមហ៊ុន Cambodia International Investment Development Group Co., Ltd. សម្រាប់គម្រោងសាងសង់រោងចក្រអគ្គិសនី ដុតធ្យូងថ្ម អនុភាព ១៣៥ មេហ្គាវ៉ាត់ នៅខេត្តព្រះសីហនុ តាមគោលការណ៍ សាងសង់-ធ្វើម្ចាស់-អាជីវកម្ម (BOO)។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញ តាមអំណាចច្បាប់ បានចុះហត្ថលេខាខាងក្រោម លើសិទ្ធិប្រទាននេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

*Kingdom of Cambodia*

រាជរដ្ឋាភិបាល

*Royal Government*

N° 65 D.T.P

ជាតិ សាសនា ព្រះមហាក្សត្រ

*Nation Religion King*

**Phnom Penh, April 25 , 2011**

# DELEGATION OF FULL POWERS

- Seen the Constitution of the Kingdom of Cambodia
- Seen the Royal Decree NS/RKT/0908/1055 dated 25 of September 2008 on the nomination of the Royal Government of Cambodia
- Seen the Royal Kram 02/NS/94 dated 20 of July 1994 promulgating the Law on the Organization and Functioning of the Council of Ministers
- Seen the Royal Kram NS/RKM/0196/18 dated 24 of January 1996 promulgating the Law on the Establishment of the Ministry of Economy and Finance
- Seen the Royal Kram 03/NS/94 dated 05 0f August 1994 promulgating the Law on Investment of Kingdom of Cambodia and the Law on Amendment of Law on Investment of Kingdom of Cambodia promulgated by the Royal Kram NS/RKM/0303/009 dated 24 of March 2003
- Seen the Royal Kram NS/RKM/1007/027 dated 19 0f October 2007 promulgating the Law on Concessions
- Seen the Royal Kram NS/RKM/1210/017 dated 22 of December 2010 promulgating the Law on Finance for Management of Fiscal Year 2011
- Seen Sub-decree 111 អនក្រ.បក dated 27 of September 2005 on Implementation of the Law on Amendment of Law on Investment of Kingdom of Cambodia

## THE ROYAL GOVERNMENT

Delegates herewith to H.E. MR. KEAT CHHON, Deputy Prime Minister, Minister of Economy and Finance, full power to sign the Implementation Agreement, and the Governmental Guarantee of Payment by the EDC/MIME to Cambodia International Investment Development Group Co., Ltd. for the Development of 135 MW Coal Fired Power Plant on BOO Basis Project in Preah Sihanouk Province.

In witness whereof the undersigned, the Prime Minister of the Kingdom of Cambodia with full powers duly entrusted to him, has signed this delegation of full powers.

Prime Minister

**Samdech Akka Moha Sena Padei Techo HUN SEN**